**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សំណុំរឿងរដ្ឋប្បវេណីលេខៈ ៨១
ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០
សាលក្រមលេខ ៤៣ (ជ)
ចុះថ្ងៃទី២៦ ខែ មីនា ឆ្នាំ ២០២០

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃព្រហស្បតិ៍ ០៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

- **ដើមចោទ ៖**

-ឈ្មោះ [redacted] **សុខបាន** ភេទស្រី អាយុ ២៩ឆ្នាំ មុខរបរនៅផ្ទះ មានទីលំនៅសព្វថ្ងៃ [redacted] មានប្តីឈ្មោះ [redacted] សុផល មានកូនចំនួន ០១នាក់ ។

តំណាងដោយអណត្តិដោយលោកមេធាវី [redacted] អត្តលេខ **១៩៣** និងលោកមេធាវី [redacted] អត្តលេខ **១៨៤៣T** នៃការិយាល័យមេធាវី [redacted] ។

- **ចុងចម្លើយ ៖**

-ឈ្មោះ [redacted] **សុផល** ភេទប្រុស អាយុ ៣២ឆ្នាំ មានទីលំនៅ [redacted] មានប្រពន្ធឈ្មោះ [redacted] សុខបាន មានកូនចំនួន ០១នាក់ ។

## ១.អង្គហេតុ និងចំណុចវិវាទ

### ១.១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១. សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] **សុផល** ។

២. សុំទាមទារគ្រប់គ្រងកូនស្រី ០១នាក់ អាយុ ០៣ឆ្នាំ ។

៣. សុំឲ្យចុងចម្លើយបង់អាហារការតព្វកិច្ចចិញ្ចឹមកូនចំនួន ១លានរៀលក្នុងមួយខែ ។

### ១.២.ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំខ្វាវ ស្រុកសំរោង ខេត្តតា



Scanned with CamScanner

កែវ ។ ក្នុងពេលរួមរស់ជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយ មានកូនស្រីម្នាក់ឈ្មោះ [redacted] សុនិតា កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧ (សំបុត្រកំណើតលេខ ៨១ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧) ។ ចំពោះទ្រព្យរួម និងបំណុលរួម រវាងដើមចោទ និងចុងចម្លើយពុំមានទេ ។ ក្នុងការរួមរស់ជាមួយគ្នាកន្លងមកដើមចោទ និងចុងចម្លើយ មានការមិនចុះសម្រុងគ្នា និងតែងតែមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ នៅពេលដែលដើមចោទទើបសម្រាលកូនបាន ០៣ខែ ចុងចម្លើយមិនបាននៅមើលថែដើមចោទ ព្រមទាំងបានចុះចោលដើមចោទ ហើយចុងចម្លើយតែងតែជេរប្រទេចដើមចោទ និងក្រុមគ្រួសារ ពេលដែលមានរឿងឈ្លោះប្រកែកគ្នាម្តងៗ ជាហេតុធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធជាមួយនឹងចុងចម្លើយ ។

**១.៣. អង្គហេតុដែលអះអាងដោយគូភាគី ៖**

**-ដើមចោទឈ្មោះ [redacted] សុខបាន បានថ្លែងការណ៍ថា:** ខ្លួននៅតែរក្សាការទាមទារដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ និងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទុកជាបានការដដែល ។ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយ កាលពីថ្ងៃ០៣ ខែមីនា ឆ្នាំ២០១៦ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ (សំបុត្រសំបុត្រអាពាហ៍ពិពាហ៍លេខ ១៤ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦) នៅឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ។ ក្នុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធជាមួយចុងចម្លើយ ខ្លួន និងចុងចម្លើយមានកូនស្រីម្នាក់ឈ្មោះ [redacted] សុនិតា អាយុ ០៣ ឆ្នាំ កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧ (សំបុត្រកំណើតលេខ៨១ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧) ។ ចំពោះទ្រព្យរួម និងបំណុលរួម រវាងខ្លួន និងចុងចម្លើយគឺគ្មានទេ ។ ក្នុងការរួមរស់ជាមួយគ្នាកន្លងមកជាមួយចុងចម្លើយ គឺមិនចុះសម្រុងគ្នា និងតែងតែមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ នៅពេលដែលខ្លួនទើបសម្រាលកូនបាន ០៣ខែ ចុងចម្លើយមិនបាននៅមើលថែខ្លួនទេ ព្រមទាំងបានចុះចោលខ្លួន ហើយឲ្យតែពេលមានរឿងឈ្លោះប្រកែកគ្នាជាមួយខ្លួន ចុងចម្លើយតែងតែជេរប្រទេចខ្លួន និងក្រុមគ្រួសារខ្លួនទៀតផង ។ មូលហេតុនេះហើយទើបធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធជាមួយនឹងចុងចម្លើយ ។ ខ្លួនសុំឲ្យតុលាការសម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ ។

**- ចុងចម្លើយឈ្មោះ [redacted] សុផល បានថ្លែងការណ៍ថា:** ខ្លួនឯកភាពនឹងការសុំលែងលះរបស់ដើមចោទ ព្រោះពិតជាអស់មនោសញ្ចេតនានឹងគ្នាប្រាកដមែន ។ ខ្លួនឯកភាពនឹងការទាមទាររបស់ដើមចោទដែលលើកឡើងថាខ្លួនបាទ និងដើមចោទបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាកាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ចំពោះមន្ត្រីអត្រានុកូលដ្ឋាន ។ ក្នុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធមានកូនម្នាក់ឈ្មោះ [redacted] **សុនិតា** ភេទស្រី អាយុ ០៣ ឆ្នាំ ខ្លួនសុខចិត្តប្រគល់ឲ្យដើមចោទគ្រប់គ្រងថែរក្សា ប៉ុន្តែខ្លួនមិនឯកភាពនឹងការទាមទារអាហារកិច្ចចិញ្ចឹមកូនទេ ព្រោះខ្លួនគ្មានលទ្ធភាពទេ ព្រោះខ្លួនជាប់បំណុលធនាគារ ។ ចំពោះការលើកឡើងរបស់ដើមចោទដែលលើកឡើងថា ទ្រព្យសម្បត្តិរួម និងបំណុលរួមគ្មាននោះ ខ្លួនសុំបដិសេធ ដោយហេតុថា ខ្លួនលក់គោរបស់ខ្លួនផ្ទាល់ចំនួន ០២ ក្បាល បានលុយប្រហែលចំនួន ៤លាន ខ្សែកមាសចំនួន ៧ជី លក់បានលុយចំនួន ១០៩០ ដុល្លាអាមេរិក សរុបបានចំនួន ២.០៩០ ដុល្លាអាមេរិក ហើយយកប្រាក់នោះមកឲ្យប្រពន្ធទិញឥវ៉ាន់រកស៊ី ។ ចំពោះបំណុលរួមមាន គឺខ្ចីធនាគារស្ថាបនាចំនួន ១០.០០០$ (មួយម៉ឺនដុល្លារអាមេរិក) ខ្ចីយកមកធ្វើផ្ទះ ហើយសព្វថ្ងៃបង់ទាំងការទាំងដើមបានមួយចំនួនហើយ

ហើយសព្វថ្ងៃនៅជំពាក់ធនាគារចំនួន ៣.៣៤៤,៦៦$ (បីពាន់បីរយសែសិបបួនដុល្លារ និងហុកសិបប្រាំមួយសេន) ចំពោះការលើកឡើងរបស់ដើមចោទដែលលើកឡើងថា ខ្លួនចុះចោលគាត់អស់រយៈពេល ០៣ ឆ្នាំនោះ ខ្លួនសុំបដិសេធ ព្រោះរឿងឈ្លោះទាស់ទែងគ្នា ហើយខ្លួនឈប់រស់នៅជាមួយគាត់ នៅឆ្នាំ២០១៨ នេះទេ ។

-ដើមចោទឈ្មោះ [redacted] **សុខបាន** បានថ្លែងការបញ្ជាក់ថាៈ ខ្លួនទទួលស្គាល់ថាគាត់ពិតជាបានលក់គោ និងខ្សែកយកលុយមកទិញឥវ៉ាន់រកស៊ីពិតមែន ប៉ុន្តែឥវ៉ាន់នោះខ្លួនបានលក់អស់ហើយ ហើយលុយដែលបានមកពីលក់ឥវ៉ាន់នោះ ខ្លួនយកមកចំណាយជាប្រចាំថ្ងៃជាមួយគាត់ និងដូរម៉ូតូឲ្យគាត់បានពីរគ្រឿង រួមទាំងចំណាយផ្សេងៗ ។ ចំពោះបំណុលរួមនោះ ខ្លួនទទួលស្គាល់ថាពិតជាបានខ្ចីពីធនាគារពិតមែន ចំនួន **១០.០០០$ (មួយម៉ឺនដុល្លារអាមេរិក)** ដោយកាត់បំណុលចាស់ចំនួន **២.៣០០$ (ពីរពាន់បីរយដុល្លារអាមេរិក)** ដូច្នេះនៅសល់ **៧.៧០០$ (ប្រាំពីរពាន់ប្រាំពីររយដុល្លារអាមេរិក)** ហើយប្រាក់នេះខ្លួនបានឲ្យគាត់ចំនួន **១.១០០$ (មួយពាន់មួយរយដុល្លារអាមេរិក)** យកទៅទិញឥដ្ឋធ្វើផ្ទះ ក្រៅពីនោះខ្លួនយកទៅចំណាយព្យាបាលគាត់រងរបួសគ្រោះថ្នាក់ចរាចរណ៍ ទាំងខ្លួន និងគាត់ រួមទាំងកូន អស់ប្រហែល **៤.០០០$ (បួនពាន់ដុល្លារអាមេរិក)** ។ ខ្លួនសំណូមពរមកតុលាការ សុំឲ្យតុលាការសម្រេចតាមការទាមទាររបស់ខ្លួន ចំណែកអាកាតព្វកិច្ចចិញ្ចឹមកូនខ្លួនសុំមិនទាមទារទេ ហើយសុំឲ្យចុងចម្លើយសងបំណុលធនាគារតែម្នាក់ឯង ព្រោះសព្វថ្ងៃខ្លួនរស់នៅម្នាក់ឯង និងចិញ្ចឹមកូនម្នាក់ទៀតផង ។

–ចុងចម្លើយឈ្មោះ [redacted] **សុផល** បានថ្លែងការណ៍បញ្ជាក់ថាៈ ខ្លួនសុខចិត្តបង់បំណុលធនាគារតែម្នាក់ឯង ។

**១.៥.ចំណុចវិវាទៈ** គ្មាន ។

## ២.ការពិនិត្យភស្តុតាង

- សំបុត្រអាពាហ៍ពិពាហ៍លេខ **១៤** ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំខ្វាវ ។
- សំបុត្រកំណើតលេខ **៨១** ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំខ្វាវ ។

## ៣.សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

### ៣.១.ស្តីពីការទាមទារទី១ ៖ ការសុំលែងលះពីចុងចម្លើយ

-ដើមចោទឈ្មោះ [redacted] **សុខបាន** និងចុងចម្លើយឈ្មោះ [redacted] **សុផល** ពិតជាប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ **១៤** ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំខ្វាវ ពិតប្រាកដមែន ។

- ភាគីដើមចោទបានប្តឹងសុំលែងលះពីចុងចម្លើយ ដោយសំអាងថា ការរស់នៅមិនចុះសម្រុងគ្នា និងតែងតែមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ ពេលដែលដើមចោទទើបសម្រាលកូនបាន ០៣ខែ ចុងចម្លើយមិន



Scanned with CamScanner

បាននៅមើលថៃដើមចោទ ព្រមទាំងបានចុះចោលដើមចោទ ហើយចុងចម្លើយតែងតែជេរប្រទេចដើមចោទ និងក្រុមគ្រួសារ ពេលដែលមានរឿងឈ្លោះប្រកែកគ្នាម្តងៗ ជាហេតុធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធជាមួយនឹងចុងចម្លើយ ។ ចំណែកឯចុងចម្លើយឯកភាពទាំងស្រុងនឹងការលើកឡើងរបស់ដើមចោទ និងសំណូមពរមកតុលាការឲ្យសម្រេចតាមការទាមទាររបស់ដើមចោទ ។ ដូចនេះឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ ហេតុនេះគប្បីតុលាការពិចារណាសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាមមាត្រា **៩៧៩** នៃក្រមរដ្ឋប្បវេណី ។

**៣.២. ស្តីពីការទាមទារទី២ ៖ ដើមចោទសុំទាមទារគ្រប់គ្រងកូន**

- ក្នុងការរួមរស់នៅជាមួយគ្នាគូភាគីអះអាងថា មានកូនស្រីម្នាក់ឈ្មោះ [redacted] **សុនិតា** កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧ មានសំបុត្រកំណើតលេខ ៨១ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំខ្វាវ ។ ចំពោះកូននេះ គូភាគីបានឯកភាពកំនត់យកម្តាយឈ្មោះ [redacted] **សុខបាន** ជាអ្នកមានអំណាចមេបា ស្របតាមមាត្រា **១០៣៧ ចំណុចទី១** នៃក្រមរដ្ឋប្បវេណី ។

**៣.៣.** ភាគីដើមចោទ ថ្លែងការណ៍ថាមិនទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូននោះទេ និងសុំឲ្យតុលាការមិនបាច់លើកមកពិចារណាទេ ហេតុនេះតុលាការមិនពិចារណាចំពោះចំណុចនេះឡើយ ។

**៣.៤.** ចំពោះទ្រព្យសម្បត្តិរួម ដើមចោទមិនបានស្នើសុំឲ្យបែងចែកទេ ដោយបានបញ្ជាក់ថា គ្មាននោះទេ ។ ចំណែកឯចុងចម្លើយបានអះអាងថា ទ្រព្យសម្បត្តិរួមមានឥវ៉ាន់ដែលប្រពន្ធរកស៊ីរាល់ថ្ងៃ ជាប្រាក់ដែលខ្លួនបានមកពីលក់គោ និងខ្សែកមាសរបស់ខ្លួនសរុបចំនួន **២.០៩០$ (ពីរពាន់កៅសិបដុល្លារអាមេរិក)** ។ ចំពោះប្រាក់នោះ ដើមចោទទទួលស្គាល់ថាខ្លួនពិតជាបានទទួលពីដើមចោទមកទិញឥវ៉ាន់រកស៊ីមែន ប៉ុន្តែឥវ៉ាន់នោះខ្លួនបានលក់អស់ហើយ ហើយប្រាក់ដែលបានមកពីលក់ឥវ៉ាន់នោះ ខ្លួនបានយកមកចំណាយប្រចាំថ្ងៃជាមួយចុងចម្លើយ ដូរម៉ូតូឲ្យចុងចម្លើយ និងចំណាយផ្សេងៗក្នុងគ្រួសារ ។ ចំណុចនេះ ដើមចោទ និងចុងចម្លើយបានបញ្ជាក់ដូចគ្នាថា ខ្លួនមិនទាមទារឲ្យតុលាការធ្វើការបែងចែកនោះទេ ។ ហេតុនេះតុលាការមិនលើកយកចំណុចនេះមកពិចារណាឡើយ ។

**៣.៥.** ចំពោះបំណុលរួម ប្រាក់ជំពាក់ធនាគារស្ថាបនា ភីអិលស៊ី ចំនួន **៣.៣៤៤,៦៦$ (បីពាន់បីរយសែសិបបួនដុល្លារ និងហុកសិបប្រាំមួយសេន)** ចុងចម្លើយឯកភាពទទួលបន្ទុកតែម្នាក់ឯង ហេតុនេះតុលាការសម្រេចតាមឆន្ទៈរបស់ភាគី ។

**៣.៦.** តាមពាក្យបណ្តឹងរបស់ភាគីដើមចោទបានទាមទារទទួលបន្ទុកប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី គប្បីតុលាការសម្រេចតាមការទាមទារនេះ ។

## ៤.សេចក្តីសម្រេចបញ្ចប់

**៤.១.** ឲ្យដើមចោទឈ្មោះ [redacted] **សុខបាន** និងចុងចម្លើយឈ្មោះ [redacted] **សុផល** បានលែងលះគ្នា ។

**៤.២.** កំណត់យកម្តាយឈ្មោះ [redacted] **សុខបាន** ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **សុនិតា** ភេទស្រី កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧ មានសំបុត្រកំណើតលេខ ៨១ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០១៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំខ្វាវ ។

ភាគីដែលពុំមានអំណាចមេបា មានសិទ្ធចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ។

**៤.៣.** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ នៅចំពោះមុខដើមចោទ និងចុងចម្លើយ និងបើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

អនុសារសាលក្រមនេះមានអានុភាពដូចមូលសាលក្រមដែរ

ថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ខេត្តកំពង់ស្ពឺ, ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]